# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤៣...សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន
## នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រធានក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន

### សម្រេច

**ប្រការ ១:** ត្រូវបានតែងតាំងសមាសភាពក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដូចខាងក្រោម ៖

| | |
|---|---|
| ១- ឯកឧត្តម ប្រាក់ សុខុន | ប្រធាន |
| ២- ឯកឧត្តម ស ចាន់ធី | អនុប្រធាន |
| ៣- ឯកឧត្តម ឈើវ យីស៊ាង | អនុប្រធាន |

www.pheakdeylaw.com

| | | |
|---|---|---|
| ៤- | ឯកឧត្តម ប្រាក់ ផល្លា | ទីប្រឹក្សា |
| ៥- | ឯកឧត្តម ពល ម៉ារ៉ាវី | សមាជិក |
| ៦- | ឯកឧត្តម ហេង សុវិន្ទ | សមាជិក |
| ៧- | ឯកឧត្តម លី សុខហេង | សមាជិក |
| ៨- | ឯកឧត្តម ទាន សំណាង | សមាជិក |
| ៩- | ឯកឧត្តម មៅ ទិត្យារុណ | សមាជិក |
| ១០- | ឯកឧត្តម សាង បូរ៉ាណា | សមាជិក |
| ១១- | ឯកឧត្តម ដារ បុត្រមុនី | សមាជិក |
| ១២- | ឯកឧត្តម សំលៀង សាលីន | សមាជិក |
| ១៣- | ឯកឧត្តម ធុច ដាលីន | សមាជិក |
| ១៤- | ឯកឧត្តម ម៉ែន ទន | សមាជិក |
| ១៥- | កញ្ញា ព្រាប កែវច័ន្ទមុនី | សមាជិក |
| ១៦- | កញ្ញា ប៉ែន ច័ន្ទដាវី | សមាជិក |
| ១៧- | កញ្ញា សាយ សារ៉ាមី | សមាជិក |
| ១៨- | កញ្ញា មាច សុភាវី | សមាជិក |
| ១៩- | លោក ទូច សុរ៉ាណា | សមាជិក ។ |

**ប្រការ ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*